# លក្ខខន្តិកៈ

## ធានារ៉ាប់រងប៊ីម៉ា អ៊ីឌីវ៉ាយស៍

## នរណានឹងទទួលបានការធានា?

ធានារ៉ាប់រងប៊ីម៉ា អ៊ីឌីវ៉ាយស៍-ម្ចាស់បណ្ណសន្យារ៉ាប់រងត្រូវតែផ្តល់ ព័ត៌មានលម្អិតពីឧបករណ៍អេឡិចត្រូនិក នៅលើគោលការណ៍ដើម្បីទទួលបានការធានានេះ។

## ការកាត់ទឹកប្រាក់ និង ការធានា:

- លក្ខខណ្ឌនៃការប្រើប្រាស់ ដើម្បីទទួលបានការធានាត្រូវបង់បុព្វលាភជាសាច់ប្រាក់នៅពេលចុះឈ្មោះជាមួយមន្ត្រីផ្នែកលក់របស់យើង។
- អត្ថប្រយោជន៍ពេញលេញនឹងទទួលបានភ្លាមៗបន្ទាប់ពីធ្វើការចុះឈ្មោះ។

  ឧទាហរណ៍:បន្ទាប់ពីមានការបង់ទឹកប្រាក់បុព្វលាភពេញលេញរួចរាល់នៅថ្ងៃទី 20 ខែមករា ការធានានឹងមានសុពលភាពក្នុងថ្ងៃខែឆ្នាំដដែល ។ គ្មានការរង់ចាំដើម្បីទទួលបានការធានាលើផលិតផលនេះ។

## ការទាមទារសំណង:

ការទាមទារសំណង អាចធ្វើទៅបានក្នុងរយៈពេល 3ខែក្នុងករណីមានបញ្ហាកើតឡើង ។ ដំណើរការផ្តល់សំណងនឹងផ្តល់បន្ទាប់ពីទទួលបានឯកសារខាងក្រោមបានគ្រប់គ្រាន់៖

- លេខ IMEI ឬលេខកំណត់អត្តសញ្ញាណឧបករណ៍អេឡិចត្រូនិក (Serial Number) និងបណ្ណធានារ៉ាប់រងអ្នកដែលត្រូវបានធានា។
- រូបថតដែលបង្ហាញពីការខូចខាតរបស់ឧបករណ៍អេឡិចត្រូនិក។
- ច្បាប់ថតចម្លងឯកសារបញ្ជាក់អត្តសញ្ញាណរបស់អ្នកដែលត្រូវទាមទារសំណង។
- របាយការណ៍ប៉ូលីស ឬអាជ្ញាធរមូលដ្ឋានបញ្ជាក់ពីកាលបរិច្ឆេទដែលបានកើតឡើង និងមូលហេតុនៃការបាត់បង់ដោយចោរកម្ម។
- ទំហំទឹកប្រាក់នៃការខូចខាត ឬចោរកម្ម។
- ឯកសារបញ្ជាក់ពីការជួសជុលរបស់ម្ចាស់បណ្ណសន្យារ៉ាប់រង (ក្នុងករណីដែលការជួសជុលត្រូវបាន យល់ព្រមពីខាងក្រុមហ៊ុន អោយអតិថិជនធ្វើការជួសជុលជាមួយហាងដែលមិនមែនជាដៃគូរបស់ក្រុមហ៊ុន មីលវីក)។
- អតិថិជនអាចទំនាក់ទំនងមកក្រុមហ៊ុនប៊ីម៉ា តាមរយៈលេខទូរសព្ទ័ រឺក៏អាចមកក្រុមហ៊ុនផ្ទាល់ដើម្បីធ្វើការទាមទារសំណង។ មីលវីក(**Milvik**) នឹងធ្វើការផ្តល់សំណងក្នុងរយៈយូរបំផុតមិនឱ្យលើសពីរយៈពេល ៣ ថ្ងៃនៃថ្ងៃធ្វើការប្រសិនបើបានដាក់ឯកសារមកគ្រប់គ្រាន់ ។

## ករណីលើកលែងមិនផ្តល់សំណង:

ផលិតផលធានារ៉ាប់រង "ប៊ីម៉ា អ៊ីឌីវ៉ាយស៍" មានករណីមួយចំនួនដែលក្រុមហ៊ុនមិនទទួលធានា និងមិនផ្តល់សំណងធានារ៉ាប់រងដល់ម្ចាស់បណ្ណសន្យារ៉ាប់រង ឬអ្នកទទួលផល ប្រសិនបើការខូតខាត ឬចោរកម្មនោះកើតឡើងបណ្តាលមកពីករណីរួមមានដូចខាងក្រោមៈ

ក- ការចូលរួមក្នុងសកម្មភាពសង្គ្រាម ភេរវកម្ម មហន្តរាយ នុយក្លេអ៊ែរ ឬកុប្បកម្ម។

ខ- ការបាត់បង់ ឬការខូចខាតណាមួយដែលត្រូវបានធានាដោយក្រុមហ៊ុនដើមផលិត ឬការធានារបស់ហាងជួសជុល ឬការធានាផ្សេងទៀតដែលនៅមានប្រសិទ្ធភាព។

គ- ឧបករណ៍អេឡិចត្រូនិកដែលមានភាពមិនប្រក្រតី ហើយត្រូវបានប្រកាសអោយយកចូលរោងចក្រផលិតឡើងវិញ។ករណីដែលអតិថិជនបានទិញកញ្ចប់ធានាសម្រាប់ ឧបករណ៍ដែលមានភាពមិនប្រក្រតីរួចរាល់មុនពេលប្រកាសរបស់ក្រុមហ៊ុនផលិតឧបករណ៍អេឡិចត្រូនិក នោះអតិថិជនអាចធ្វើការស្នើសុំនូវចំនួនបុព្វលាភ ដែលបានបង់មកក្រុមហ៊ុន នូវបុព្វលាភតាមអត្រាសមាមាត្ររយៈពេលកិច្ចសន្យាដែលនៅមានសុពលភាព ចំពោះករណីមិនមានការទាមទារសំណងធានារ៉ាប់រងត្រូវបានធ្វើឡើង។

ឃ- ការខូចខាតណាមួយដែលមិនប៉ះពាល់ដល់ប្រតិបត្តិការ ឬមុខងារធម្មតារបស់ឧបករណ៍ដែលបានធានារ៉ាប់រងមានដូចជាគ្រឿងបន្លាស់ដែលប្រើក្នុង ឬជាមួយឧបករណ៍ដែលត្រូវបានធានាដូចជា ខ្សែតភ្ជាប់អូឌីយ៉ូ ឬវីដេអូ និងខ្សែតភ្ជាប់ផ្សេងៗខាងក្រៅ។

ង- កម្មវិធី ឬ Software (រួមទាំងប្រព័ន្ធប្រតិបត្តិការ កម្មវិធីរបស់ឧបករណ៍អេឡិចត្រូនិក និងទិន្នន័យដែលបានរក្សាទុក) ការខូចខាតដែលកើតឡើងដោយផ្ទាល់ពីការដំឡើងកម្មវិធី និង/ឬការដកចេញ មេរោគកុំព្យូទ័រ ការការពារមេរោគ និងគ្រឿងកុំព្យូទ័រផ្សេងទៀត។

ច- ការខូចខាតណាមួយដែលកើតឡើងបន្ទាប់ពីការជួសជុលដែលធ្វើឡើងដោយអ្នកជួសជុល ឬហាងផ្តល់សេវាកម្មជួសជុលដែលមិនមានការអនុញ្ញាតចំពោះឧបករណ៍ដែលបានធានា។

ឆ- កំហុសបច្ចេកទេសខាងក្រៅដូចជាការតខ្សែភ្លើង ការតភ្ជាប់អគ្គិសនី វ៉ុលថាមពល ឬចរន្ត ការតម្រឹមការទទួលសញ្ញាឡើងវិញ (ការទទួលខ្សោយ)។

ជ- ការខូចខាតដោយចៃដន្យណាមួយដែលបង្កឡើងដោយផ្ទាល់ ឬដោយប្រយោល ឬបណ្តាលមកពីៈ

(១)- ការបែកបាក់ ការដំណើរការខុសប្រក្រតី ឬការខូចខាតដោយចៃដន្យ ដែលបណ្តាលមកពីការដំឡើងមិនត្រឹមត្រូវ ឬការដំឡើងឡើងវិញខុសនូវកម្មវិធី (software) ឬការមិនអនុវត្តតាមការណែនាំអំពីប្រតិបត្តិការ ឬការណែនាំរបស់អ្នកផលិតឧបករណ៍ដែលបានធានា។

(២)- ភាពអន់ខ្សោយបន្តិចម្តងៗនៃឧបករណ៍ដែលបានត្រូវបានធានា ឬការខូចខាតណាមួយដែលមិនអាចកំណត់បានដោយព្រឹត្តិការណ៍តែមួយ។

(៣)- សំណើម ញើស ច្រែះ ធូលី ឬការប្រែប្រួលសីតុណ្ហភាព លុះត្រាតែត្រូវបានកំណត់គុណលក្ខណៈដោយផ្ទាល់ទៅនឹងការខូចខាតដោយចៃដន្យភ្លាមៗ និងមិនបានមើលឃើញទុកជាមុន ដូចជាការប៉ះដោយចៃដន្យជាមួយនឹងទឹក ឬវត្ថុរាវផ្សេងទៀត។

(៤)- ទង្វើណាមួយដូចជា ការប្រើប្រាស់មិនត្រឹមត្រូវ ឬនរណាម្នាក់ដែលត្រូវបានអនុញ្ញាតដោយម្ចាស់បណ្ណសន្យារ៉ាប់រងដើម្បីប្រើប្រាស់ឧបករណ៍ដែលត្រូវបានធានារ៉ាប់រង ឬការប្រើប្រាស់ដោយធ្វេសប្រហែសដូចជា៖ ការបោះ ឬគ្រវែងឧបករណ៍បន្ទាប់ពីប្រើប្រាស់រួច ហើយបណ្តាលអោយជ្រុះ ឬធ្លាក់បែក ។

ឈ- ការបាត់បង់ដែលមិនដឹងពីមូលហេតុ ឬការទុកដាក់ឧបករណ៍ដែលត្រូវបានធានាមិនត្រឹមត្រូវ ឬធ្វេសប្រហែសដូចជា៖ ករណីទុកឧបករណ៍ចោលនៅទីកន្លែងសាធារណៈ។

ញ- ការខូចខាតណាមួយដែល៖

(១)- ម្ចាស់បណ្ណសន្យារ៉ាប់រងមិនអាចបង្ហាញឧបករណ៍ដែលរងការខូចខាតបាន។

(២)- លេខ IMEI ឬ លេខកំណត់អត្តសញ្ញាណឧបករណ៍ មិនអាចកំណត់អត្តសញ្ញាណបាន ហើយទំនោរនៃការខូចខាតមិនបង្ហាញឱ្យឃើញពីការខូចខាតដល់លេខ IMEI ឬ លេខដែលកំណត់អត្តសញ្ញាណឧបករណ៍។

(៣)- លេខ IMEI ឬ លេខកំណត់អត្តសញ្ញាណឧបករណ៍មិនត្រូវបានបង្ហាញ។

ដ- រាល់ការបាត់បង់ ឬសំណងណាមួយដែលម្ចាស់បណ្ណសន្យារ៉ាប់រងបានទាមទារ ឬបានទទួលសំណងក្រោមទម្រង់នៃសំណងផ្សេងទៀត រួមទាំងប៉ុន្តែមិនកំណត់ចំពោះគោលការណ៍ ឬគោលការណ៍ធានារ៉ាប់រងផ្សេងទៀតឡើយ។

ឋ- ការបាត់បង់ដោយសារការលួច ឆក់ ឬប្លន់ទៅលើឧបករណ៍ដែលត្រូវបានធានាដោយមិនបានរាយការណ៍ដោយផ្ទាល់ទៅប៉ូលីស ឬអាជ្ញាធរមានសមត្ថកិច្ចក្នុងរយៈពេល ៤៨ ម៉ោង បន្ទាប់ពីការកើតហេតុនៃអំពើចោរកម្ម ហើយមិនមានរបាយការណ៍ប៉ូលីសបញ្ជាក់ពីករណីចោរកម្ម។

## ការលុបចោលការធានា:

គោលការណ៍នៃការធានាអាចធ្វើការលុបចោលបានដោយធ្វើការទាក់ទងទៅកាន់ផ្នែកបម្រើសេវាអតិថិជនរបស់មីលវីក (Milvik) ឬមកកាន់ការិយាល័យក្រុមហ៊ុនមីលវីក(Milvik) ដើម្បីយកប្រាក់បង្វិល 90%វិញនៃបុព្វលាភតាមអត្រាសមាមាត្ររយៈពេលកិច្ចសន្យាដែលនៅមានសុពលភាព ចំពោះករណីមិនមានការទាមទារសំណងធានារ៉ាប់រងត្រូវបានធ្វើឡើង។